

# ការធ្វើតាមព្រះយេស៊ូវនៅ ប្រទេសនេប៉ាល់





## ជួបជាមួយ សាមយុគ !





### អំពី សាមយុគ

អាយុ ៖ ៩ ឆ្នាំ

មកពី ៖ ខេត្ត បាមេទី ប្រទេសនេប៉ាល់

ភាសា ៖ ភាសានេប៉ាល់ ភាសាអង់គ្លេស

គោលដៅ និង ក្ដីសុបិន ៖ ១ ) ធ្វើជាអ្នកបើកយន្តហោះ ។ ២ ) ធ្វើតាមព្រះយេស៊ូវគ្រីស្ទ ៣ ) ដាក់ឈ្មោះកូនប្រុសដំបូងរបស់គាត់ថា « ស្រ៊ីចល » ដែលមានន័យថា បរិសុទ្ធ ។

គ្រួសារ ៖ សាមយុគ, អាម៉ា ( ម៉ាក់ ), បាបា ( ប៉ា ) និង ឌីឌីសពីរនាក់ ( បងស្រី )

## របៀបដែលសាមយុគធ្វើតាមព្រះយេស៊ូវ

នៅប្រទេសនេប៉ាល់ មនុស្សមិនច្រើនទេដែលជាគ្រិស្តសាសនិក ។ មនុស្សជាច្រើនមិនបានដឹងអំពីព្រះយេស៊ូវគ្រីស្ទសោះឡើយ ។ សាមយុគចូលចិត្តប្រាប់អ្នកដទៃទៀតអំពីព្រះយេស៊ូវ ។

មានពេលមួយ សាលារៀនរបស់សាមយុគបានប្រារព្ធពិធីបុណ្យគ្រីស្ទម៉ាសដើម្បីជួយសិស្សឲ្យស្វែងយល់ពីបុណ្យឈប់សម្រាកនានានៅទូទាំងពិភពលោក ។ សាមយុគបានចែកចាយថាគាត់ជាគ្រីស្ទាន ។ គាត់បានឆ្លើយតបសំនួររបស់គ្រូ។ និងមិត្តរួមថ្នាក់អំពីព្រះយេស៊ូវគ្រីស្ទ ។

សាមយុគបាននិយាយថា « ខ្ញុំចង់ធ្វើតាមព្រះយេស៊ូវគ្រីស្ទពេញមួយជីវិតរបស់ខ្ញុំ » ។●



### ប្អូនក៏អាចធ្វើតាមព្រះយេស៊ូវបានដែរ !

មានវិធីជាច្រើនដើម្បីធ្វើតាមព្រះយេស៊ូវ ។ តើប្អូនធ្វើតាមទ្រង់តាមរបៀបណា ?
សូមសរសេរប្រាប់យើងផង !

### ចំណង់ចំណូលចិត្តរបស់សាមយុគ

**ដំណើររឿងអំពីព្រះយេស៊ូវ ៖**
ទ្រង់សុគតដើម្បីយើង ដោយសារទ្រង់ស្រឡាញ់យើង ។

**ចម្រៀងកុមារ ៖**
« ធ្វើតាមព្យាការី » (*សៀវភៅចម្រៀងកុមារ* ទំព័រ ៥៨–៥៩ )



**ទីកន្លែង ៖**
បន្ទប់ទទួលភ្ញៀវនៅផ្ទះគាត់



**អាហារ ៖**
នំខេក និង ឃួខ្វា ( សាច់មាន់ )



**ពណ៌ ៖**
ពណ៌ទឹកក្រូច និងពណ៌ខៀវ



**មុខវិជ្ជានៅសាលា ៖**
វិទ្យាសាស្ត្រ និងគណិតវិទ្យា

